# កម្មវិធី អ្នកថែទាំបងប្អូនប្រុសរបស់ខ្ញុំ

## ទីក្រុងឡុងប៊ិច




CITY OF
LONGBEACH

# ការប្រកួតជាប្រវត្តិសាស្ត្រ ឱកាសដែលពុំធ្លាប់មានពីមុនមក

នៅខែកុម្ភៈ ឆ្នាំ 2014 ប្រធានាធិបតី អូបាម៉ា បានចាប់ផ្តើមកម្មវិធីផ្តួចផ្តើមគំនិត *អ្នកថែទាំបងប្អូនប្រុសរបស់ខ្ញុំ* (MBK) ដើម្បីដោះស្រាយបញ្ហាគម្លាតឱកាសដែលបន្តកើតមានចំពោះកុមារា និងក្មេងប្រុសស្បែកខ្មៅ។ ក្រោយមកនៅឆ្នាំដដែល រដ្ឋបាលលោក អូបាម៉ា បានដាក់ចេញនូវបញ្ហាប្រឈមក្នុងសហគមន៍ MBK ដែលជាការអំពាវនាវឱ្យចាត់វិធានការសម្រាប់ទីក្រុង ទីប្រជុំជន ប្រទេស និងជាតិកុលសម្ព័ន្ធនានា ដើម្បីបង្កើត និងអនុវត្តផែនការ “ការចូលមហាវិទ្យាល័យ និងធ្វើការងារ” ដែលមានព្រឹត្តិការណ៍ចំនួនប្រាំមួយសម្រាប់ភាពជោគជ័យ។ ដោយដឹងថា ទីក្រុងមានជំហរច្បាស់លាស់ក្នុងការក្លាយជាសហគមន៍ MBK ក្រុមប្រឹក្សាទីក្រុងឡុងប៊ិចបានណែនាំឱ្យអ្នកគ្រប់គ្រងទីក្រុងរាយការណ៍អំពីរបៀបដែលទីក្រុងអាចឆ្លើយតបនឹងបញ្ហាប្រឈម និងកែលម្អស្ថានភាពសម្រាប់កុមារា និងក្មេងប្រុសស្បែកខ្មៅនៅក្នុងទីក្រុងឡុងប៊ិច។ នៅខែមករា ឆ្នាំ 2015 ក្រុមប្រឹក្សាទីក្រុងបានទទួលយកបញ្ហាប្រឈមរបស់សហគមន៍ MBK នេះ។



អភិបាលក្រុង Garcia បានប្រមូលផ្តុំក្រុមការងារ MBK នៃទីក្រុងឡុងប៊ិច (ក្រុមការងារ), ដែលជាក្រុមដ៏ធំមួយ រួមមាន អ្នកតំណាងជាង 40 នាក់ ដូចជាមន្ត្រីសាលាក្រុង អ្នកអប់រំ មន្ត្រីអនុវត្តច្បាប់ ថ្នាក់ដឹកនាំមន្ទីរពេទ្យក្នុងមូលដ្ឋាន អង្គការសហគមន៍ និងអង្គការសាសនា។ ក្រុមការងារនេះ មានបុគ្គលិកមកពីការិយាល័យអភិបាលក្រុង សេវាអភិវឌ្ឍន៍ទីក្រុងឡុងប៊ិច និងក្រសួងបច្ចេកវិទ្យា និងនវានុវត្តន៍។ Bloomberg Associates និង PolicyLink បានផ្តល់ការប្រឹក្សាយោបល់ដោយផ្អែកលើប្រយោជន៍សាធារណៈ ទៅកាន់មន្ត្រីសាលាក្រុង និងក្រុមការងារ ស្តីពីការបង្កើតផែនការសកម្មភាពក្នុងមូលដ្ឋាន MBK។ ក្រុមការងារនេះ ធ្វើកាជួបជុំគ្នានៅអំឡុងឆ្នាំ 2015 និងជួបជុំគ្នាម្តងទៀតនៅខែកុម្ភៈ ឆ្នាំ 2016។ អំឡុងពេលជួបជុំគ្នាទាំងនេះ សមាជិកក្រុមការងារត្រួតពិនិត្យឡើងវិញនូវនីតិវិធីនានាក្នុងកិច្ចប្រជុំកំពូល ផ្តល់នូវព័ត៌មាន និងធ្វើការបោះឆ្នោតដើម្បីកំណត់អាទិភាពពីអ្វីដែលបានស្នើសុំពីសំណាក់សេតវិមាន ដែលមានភាពស័ក្តិសមបំផុតសម្រាប់ទីក្រុងឡុងប៊ិច។ តាមរយៈការពិភាក្សាជាច្រើន ព័ត៌មាន និងការយល់ដឹងនានា បានកើតចេញពីដំណើរការនេះ និងបង្កើតបានជាផែនការសកម្មភាពក្នុងមូលដ្ឋាន MBK។

# កម្មវិធីអ្នកថែទាំបងប្អូនប្រុសរបស់ខ្ញុំ
## ទីក្រុងឡុងប៊ិច

## ព្រឹត្តិការណ៍សំខាន់ៗ នៃផែនការសកម្មភាពក្នុងមូលដ្ឋាន

### ព្រឹត្តិការណ៍ 01

**ចូលសាលារៀនត្រៀមខ្លួនសិក្សា**

កុមារទាំងអស់គួរតែត្រៀមខ្លួនជាស្រេចសម្រាប់ការចាប់ផ្តើមចូលរៀន – ទាំងផ្នែកចំណេះដឹង រាងកាយ សង្គម និងអារម្មណ៍។

**ដំណោះស្រាយ**

បង្កើតផែនការអប់រំកុមារតូចនៅទូទាំងក្រុង មត្តេយ្យសិក្សាទូទៅ កិច្ចសហការចុះសួរសុខទុក្ខតាមលំនៅឋាននៅទីក្រុងឡុងប៊ិច។

### ព្រឹត្តិការណ៍ 02

**អានតាមកម្រិតសិក្សាត្រឹមថ្នាក់ទីបី**

កុមារទាំងអស់គួរតែអានតាមកម្រិតសិក្សាត្រឹមអាយុប្រាំបីឆ្នាំ។ អាយុអានដើម្បីរៀនយល់ដឹង និងមិនមែនរៀនអាន គឺជាកត្តាដ៏សំខាន់មួយ។

**ដំណោះស្រាយ**

យុទ្ធនាការរបស់ទីក្រុងឡុងប៊ិចសម្រាប់ការអានតាមកម្រិតសិក្សា

មណ្ឌលសិក្សារួមនៅទីក្រុងឡុងប៊ិច (LBUSD)

ផែនការគណនេយ្យភាពគ្រប់គ្រងមូលដ្ឋាន (LCAP)

ដៃគូអាន និងគ្រូបង្រៀនអក្សរសាស្ត្រ

### ព្រឹត្តិការណ៍ 03

**បញ្ចប់មធ្យមសិក្សាត្រៀមខ្លួនចូលមហាវិទ្យាល័យ និងធ្វើការ**

កុមារអាមេរិកទាំងអស់គួរតែមានជម្រើសសិក្សាថ្នាក់មហាវិទ្យាល័យ។

**ដំណោះស្រាយ**

ការសន្យារបស់មហាវិទ្យាល័យទីក្រុងឡុងប៊ិច

យុទ្ធនាការ LBUSD *All In*

កម្មវិធីណែនាំអំពី *សុវត្ថិភាពទីក្រុងឡុងប៊ិច*

### ព្រឹត្តិការណ៍ 04

**បញ្ចប់ថ្នាក់មហាវិទ្យាល័យ ឬការបណ្តុះបណ្តាល**

ជនជាតិអាមេរិកទាំងអស់គួរតែទទួលបានការអប់រំ និងការបណ្តុះបណ្តាលដែលត្រូវការសម្រាប់ការងារប្រកបដោយគុណភាពនៅថ្ងៃនេះ និងថ្ងៃស្អែក។

**ដំណោះស្រាយ**

កម្មវិធីសិក្សាថ្នាក់មហាវិទ្យាល័យសហគមន៍នៃទីក្រុងឡុងប៊ិច; សកលវិទ្យាល័យរដ្ឋកាលីហ្វ័រញ៉ា; កម្មវិធីទីក្រុងឡុងប៊ិច

ហេដ្ឋារចនាសម្ព័ន្ធសម្របសម្រួលសម្រាប់យុវជន; កម្មវិធីបណ្តុះបណ្តាល និងឱកាស

### ព្រឹត្តិការណ៍ 05

**ចូលធ្វើការដោយជោគជ័យ**

អ្នកដែលចង់បានការងារធ្វើគួរតែអាចទទួលបានការងារមួយ ដែលអាចឱ្យពួកគេទ្រទ្រង់ជីវភាពរបស់ខ្លួន និងគ្រួសារ។

**ដំណោះស្រាយ**

ការប្រជែងកម្មសិក្សានៃទីក្រុងឡុងប៊ិចរបស់អភិបាលទីក្រុងឡុងប៊ិចដំបូងបំផុត លោក Robert Garcia

កម្មវិធីការងារយុវជន

### ព្រឹត្តិការណ៍ 06

**សុវត្ថិភាពពីអំពីហិង្សា និងទទួលបានឱកាសជាលើកទី២**

កុមារទាំងអស់គួរតែមានសុវត្ថិភាពពីអំពើឧក្រិដ្ឋកម្មហិង្សា ហើយអ្នកដែលត្រូវបានឃុំឃាំងគួរតែទទួលបានការអប់រំ ការបណ្តុះបណ្តាល និងការផ្តល់ឱកាសជាលើកទី២។

**ដំណោះស្រាយ**

យុវជនអនាគតល្អ ក្តីសង្ឃឹមនៅថ្ងៃស្អែក (PATH)

ស្មារតីភាពយុត្តិធម៌

កំណែទម្រង់ការឃុំឃាំងអនីតិជន

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីអ្នកថែទាំបងប្អូនប្រុសរបស់ខ្ញុំ នៅទីក្រុងឡុង
ប៊ិច សូមទៅកាន់គេហទំព័រ www.mbklongbeach.com ។

CITY OF
LONG**BEACH**

សេវាអភិវឌ្ឍន៍ទីក្រុងឡុងប៊ិច
**333 W. Ocean Blvd., 3rd Floor**
**Long Beach, CA 90802**

សូមទៅកាន់ **www.lbds.info**

**facebook.com/LongBeachDevelopmentServices**

**@LongBeachDS**

ព័ត៌មាននេះអាចរកបានក្នុងទម្រង់ផ្សេងទៀត ដោយស្នើសុំទៅលេខ (562) 570-3807។
សម្រាប់ទម្រង់អេឡិចត្រូនិចនៃខិត្តប័ណ្ណនេះ សូមទៅកាន់គេហទំព័រយើងខ្ញុំ www.lbds.info.